រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០០

# សេចក្តីសំរេចលេខ ៣២ សសរ

## ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារគំរោងជំនួយបច្ចេកទេស របស់ធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់អភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិកម្ពុជា

## ( ២០០០-២០០៣ )

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- យោងតាមកិច្ចព្រមព្រៀង របស់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី ១២-១១-៩៩ ស្តីពីការផ្តល់ជំនួយបច្ចេកទេសដំណាក់កាលទី ៣ ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិកម្ពុជា
- តាមសំណើរបស់ក្រសួងផែនការ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការដឹកនាំការងារ ( Steering Committee ) គំរោងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់អភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ កម្ពុជា ( ២០០០-២០០៣ ) ។

**ប្រការ ២ :** សមាសភាពគណៈកម្មាធិការដឹកនាំការងារនេះរួមមាន :

| | | | | |
|---|---|---|---|---|
| ១ | -ឯកឧត្តម | ឆាយ ថន | រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| ២ | -ឯកឧត្តម | ឡូយ ព្រហស្ថ | រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៣ | -ឯកឧត្តម | ឈៀង យ៉ាណារ៉ា | អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤ | -ឯកឧត្តម | សុខ ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥ | -ឯកឧត្តម | អ៊ិត ចាយ | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៦ | -ឯកឧត្តម | កោ ខុនដារ៉ែត | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៧ | -ឯកឧត្តម | Urooj Malik | តំណាងធនាគារអភិវឌ្ឍន៍អាស៊ី | សមាជិក |
| ៨ | -ឯកឧត្តម | សន ស៊ីថន | នាយកវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |

| | | | | |
|---|---|---|---|---|
| ៩ | -លោក | ខួន ថាទះ | អគ្គនាយករងក្រសួងផែនការ | សមាជិក |
| ១០ | -លោកស្រី | អ៊ូ ទំទី | អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១ | -លោក | កែវ សុទន្តិ | ប្រធាននាយកដ្ឋានក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២ | -លោក | ញាណ ស្រស់ | ប្រធាននាយកដ្ឋានក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៣ | -លោក | សៅ សំអ៊ិ | ប្រធាននាយកដ្ឋានក្រសួងទេសចរណ៍ | សមាជិក |
| ១៤ | -លោក | ជា ទុចណា | ប្រធាននាយកដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥ | -លោក | ចាយ សាគុណ | អនុប្រធាននាយកដ្ឋានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៦ | -លោក | ទាំ ស៊ីមស៊ុរិយា | អនុប្រធាននាយកដ្ឋានក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧ | -លោក | នាក់ សារិន | អនុប្រធាននាយកដ្ឋានធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៨ | -លោក | អ៊ុយ សារិន | ប្រធានការិយាល័យពិនិត្យការតម្លៃ និងផ្សារ | សមាជិក |

ប្រការ ៣ ៖ គណៈកម្មាការដឹកនាំការងារនេះមានភារកិច្ចដូចតទៅ ៖

-ផ្តល់ទិសដៅ និង ណែនាំ សំរាប់ជាមូលដ្ឋានក្នុងការប្រតិបត្តិការជំនួយបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ីជំពូកទី ៣ ( TA N0 3293 ) ។

-ដោះស្រាយរាល់បញ្ហាគោលនយោបាយ និងបច្ចេកទេស ក្នុងការអនុវត្តន៍កម្មវិធីរួមរបស់គំរោង ។

-ណែនាំតាមដានមើលការអនុវត្តន៍គោលនយោបាយរួម នៃការសំរបសំរួល និងសហប្រតិបត្តិការស្ថិតិជាមួយបណ្តាភ្នាក់ងាររាជរដ្ឋាភិបាល ។

-បង្កើត និងអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិតំបន់ ។

-ពង្រឹងភាព និងសមត្ថភាព នៃអង្គភាពបណ្តុះបណ្តាលស្ថិតិ ។

-ធ្វើបញ្ជី និង ដោះស្រាយកិច្ចការស្ថិតិជាន់គ្នា និងកង្វះខាតទិន្នន័យស្ថិតិ ក្នុងសកម្មភាពស្ថិតិ ។

-វាយតំលៃ និងសំរេច នូវវិធីសាស្ត្រសមស្រប សំរាប់ការអង្កេតតាមវិស័យ ក៏ដូចជាការអង្កេតពាក់ព័ន្ធគ្របវិស័យ ។

-រៀបចំបណ្តាញការងាររវាងភ្នាក់ងាររាជរដ្ឋាភិបាលនានា ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍គណនេយ្យជាតិ ។

ប្រការ ៤ ៖ គណៈកម្មាធិការដឹកនាំការងារនេះត្រូវបង្កើត លេខាធិការបច្ចេកទេស សំរាប់ជាជំនួយការដែលមានទីតាំងនៅក្រសួងផែនការ ។

ប្រការ ៥ : សមាជិកគណៈកម្មាធិការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានដឹកនាំប្រជុំជំនួស ។

ប្រការ ៦ : គណៈកម្មាធិការដឹកនាំការងារនេះ ត្រូវប្រជុំសាមញ្ញរាល់បីខែម្តង ដើម្បីពិគ្រោះ និងពិភាក្សាលើរបៀបវារៈដែលរៀបចំឡើងដោយលេខាធិការដ្ឋានបច្ចេកទេស ។ ក្នុងករណីមានការងារចាំបាច់ ត្រូវប្រជុំវិសាមញ្ញ ។

ប្រការ ៧ : គណៈកម្មាធិការដឹកនាំការងារនេះ អាចអញ្ជើញមន្ត្រីជំនាញតាមស្ថាប័នពាក់ព័ន្ធ ឲ្យមកចូលរួមប្រជុំ និងពិគ្រោះការងារជំនាញតាមការចាំបាច់ ។

ប្រការ ៨ : គណៈកម្មាធិការដឹកនាំការងារនេះ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងផែនការ ។

ប្រការ ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលធនាគារជាតិនៃកម្ពុជា ឯកឧត្តម លោក លោកស្រី ដូចមានក្នុងប្រការ ២ មានភារកិច្ចរៀងខ្លួនអនុវត្តសេចក្តីសម្រេចនេះ តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០០

## សេចក្តីសម្រេចលេខ ៣៣ សសរ

## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល